# BLACKBERRY CLIENT
# កិច្ចព្រមព្រៀងអាជ្ញាប័ណ្ណសម្រាប់អ្នកប្រើ

សូហ្វែរសម្រាប់ម៉ាស៊ីនរណប នេះ ("**Client**") ត្រូវបានផ្តល់ជូនដោយក្រុមហ៊ុន BlackBerry Limited ឬក្រុមហ៊ុនសាខា ឬក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន ("**BLACKBERRY**") ហើយត្រូវបានផ្តល់ជូន សម្រាប់ឲ្យប្រើតែជាមួយនឹងសេវាកម្ម និងសូហ្វវែរហ្វេរម៉ាស៊ីនមេរបស់សហគ្រាសដែលពាក់ព័ន្ធ ("**សូហ្វែរម៉ាស៊ីនមេ**") ដែលប្រើជាមួយនឹងសូហ្វែរសម្រាប់ម៉ាស៊ីនរណប  ព្រមទាំងកម្មវិធីទាំងអស់ដែលបានរៀបចំគ្រប់គ្រងរួចរាល់ (**នឹងមានពន្យល់ជូនខាងក្រោម**) (ជារួមហៅថា “ **សូហ្វែរសម្រាប់ម៉ាស៊ីនរណប**”) ដោយនៅទីនេះមានន័យសំដៅលើ " **Solution**" ។

ដើម្បីតម្លើងកម្មវិធី ធ្វើវាឲ្យវាដំណើរការ ឬប្រើសូហ្វែរសម្រាប់ម៉ាស៊ីនរណបណាមួយ អ្នកត្រូវតែ (ក) ៖ បាន (i) ចុះកិច្ចសន្យាជាមួយនឹង BLACKBERRY នូវកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណដំណោះស្រាយ BlackBerry សម្រាប់ដំណោះស្រាយ  ដោយរួមទាំង លក្ខខ័ណ្ឌយល់ព្រមថែមថយណាមួយ ដែលពាក់ព័ន្ធនឹងដំណោះស្រាយ (“**BBSLA**”) តាងនាមឲ្យរូបអ្នក និង (ii) ក្នុងករណីដែលអាចកើតមាន បើជាការតម្រូវសម្រាប់ដំណោះស្រាយ របស់អ្នក និងបង់ថ្លៃសេវាកម្ម សម្រាប់អាជ្ញាប័ណ្ណសិទ្ធិប្រើប្រាស់របស់ម៉ាស៊ីនរណបប្រភេទនេះ សម្រាប់ការតម្លើង ការធ្វើឲ្យវាដំណើរការ និងការប្រើប្រាស់នូវគ្រឿងទន់របស់ម៉ាស៊ីនរណបនៅក្នុងម៉ាស៊ីនរបស់អ្នក ឬ (ខ) បានទទួលសិទ្ធិឲ្យតម្លើង ធ្វើឲ្យដំណើរការ និងប្រើសូហ្វែរសម្រាប់ម៉ាស៊ីនរណប តាងនាមឲ្យនិយោជករបស់អ្នក ឬនីតិបុគ្គលដទៃទៀត ("**អង្គភាពដែលបានទទួលអាជ្ញាប័ណ្ណ**") ដែលបាន ៖ (i) ចុះកិច្ចសន្យាអាជ្ញាប័ណ្ណ BBSLA (ii) ធ្វើឲ្យអ្នកបានដឹង អំពីល័ក្ខខ័ណ្ឌនៃការប្រើរបស់អ្នកចំពោះគ្រឿងទន់ម៉ាស៊ីនរណប ក្រោមអាជ្ញាប័ណ្ណ BBSLA (iii) យល់ព្រមក្នុងការទទួលខុសត្រូវសម្រាប់ការប្រើរបស់អ្នក ចំពោះគ្រឿងទន់ម៉ាស៊ីនរណប និង (iv) ក្នុងករណីដែលអាចកើតមាន បើជាការតម្រូវនូវអង្គភាពរបស់អ្នកដែលមានអាជ្ញាប័ណ្ណដំណោះស្រាយ បានទទួល និងបង់ថ្លៃសេវាកម្ម សម្រាប់អាជ្ញាប័ណ្ណសិទ្ធិប្រើប្រាស់របស់ម៉ាស៊ីនរណប សម្រាប់ការតម្លើង ការធ្វើឲ្យដំណើរការ និងការប្រើប្រាស់នូវសូហ្វែរសម្រាប់ម៉ាស៊ីនរណប ប្រភេទនេះនៅក្នុងម៉ាស៊ីនរបស់អ្នក ។

ស្ថាប័នរបស់អ្នក អាចប្រើប្រាស់ **Solution** ដើម្បីធ្វើការគ្រប់គ្រងកម្មវិធីលើឧបករណ៍ចល័ត (ហៅថា "**MAM**”) ដោយផ្តល់ជូនអ្នក នូវកម្មវិធី ដែលបានបង្កើតឡើង ដើម្បីដំណើរការលើបំណែកឧបករណ៍ផ្ទាល់ខ្លួន ឬនៅកន្លែងការងាររបស់អ្នក  (ហៅថា " **កម្មវិធីដែលបានរៀបចំគ្រប់គ្រងរួចរាល់**”) ដែលរួមបញ្ចូលនូវកម្មវិធីគ្រឿងទន់ ដែលបានផ្តល់ជូនដោយតតិយជន។ កម្មវិធីប្រភេទនេះ ក្រោមអាជ្ញាប័ណ្ណ BBSLA ត្រូវបានគិតថាជាសូហ្វែររបស់តតិយជន ។ គ្រឿងទន់របស់តតិយជន អាចរួមបញ្ចូលនូវល័ក្ខខ័ណ្ឌយល់ព្រមចំពោះកិច្ចព្រមព្រៀងបន្ថែម រវាងអ្នក ឬអង្គភាពរបស់អ្នកដែលមានអាជ្ញាប័ណ្ណ និងអ្នកផ្គត់ផ្គង់គ្រឿងទន់របស់តតិយជន ដែលគ្រប់គ្រងលើការប្រើប្រាស់របស់គ្រឿងទន់ទាំងនោះ ។ ក្រុមហ៊ុន  BLACKBERRY នឹងមិនទទួលខុសត្រូវចំពោះគ្រឿងទន់របស់តតិយជនឡើយ ហើយគ្រប់សំណួរ និងការព្រួយបារម្ភនានាស្តីអំពីគ្រឿងទន់របស់តតិយជន ត្រូវទាក់ទងជាមួយនឹងអ្នកផ្គត់ផ្គង់គ្រឿងទន់របស់តតិយជនដែរ ។

ស្ថាប័នរបស់អ្នក អាចប្រើប្រាស់ Solution ដើម្បីធ្វើការគ្រប់គ្រងឧបករណ៍ចល័ត (ហៅថា "**MDM**") លើឧបករណ៍របស់អ្នក ដែលរួមបញ្ចូលការប្រមូលព័ត៌មានផ្ទាល់ខ្លួន។ ស្ថាប័នរបស់អ្នក គឺទទួលខុសត្រូវប្រមូល ពិនិត្យ ប្រើប្រាស់  និងគ្រប់គ្រងព័ត៌មានទាំងអស់ ដែលបានប្រមូលដោយប្រើ Solution។

បន្ថែមពីលើល័ក្ខខ័ណ្ឌយល់ព្រមខាងលើ
បើអ្នកបានទទួលនូវគ្រឿងទន់ម៉ាស៊ីនរណបណាមួយពីហាងកម្មវិធី iTunes របស់ Apple (Apple’s iTunes App Store) គឺមានន័យថាអ្នកទទួលស្គាល់ និងយល់ព្រមតាងនាមឲ្យអង្គភាពដែលមានអាជ្ញាប័ណ្ណ
គឺតាងនាមឲ្យអង្គភាពណាដែលអ្នកបានទទួលសិទ្ធិឲ្យតម្លើង ធ្វើឲ្យដំណើរការ និងប្រើនូវគ្រឿងទន់របស់ម៉ាស៊ីនរណប ឬប្រសិនបើអ្នកមិនបានទទួលសិទ្ធិពីណាទេ គឺមានន័យថាអ្នកទទួលស្គាល់ និងយល់ព្រម ក្នុងនាមខ្លួនអ្នកថា (i)   Apple
មិនមានការទទួលខុសត្រូវលើអ្វីគ្រប់យ៉ាងចំពោះគ្រឿងទន់របស់ម៉ាស៊ីនរណបប្រភេទនេះ រួមទាំងការមិនកំណត់លើការដំណើរការ ការថែទាំ និងការគាំទ្ររបស់ខ្លួន ឬសម្រាប់ការទាមទារណាមួយដោយតតីយជនដែលថា
គ្រឿងទន់ម៉ាស៊ីនរណបបែបនេះបានរំលោភលើកម្មសិទ្ធិបញ្ញារបស់តតីយជនណាមួយ ។ ចំពោះករណីដែលអាចកើតមាន ប្រសិនបើគ្រឿងទន់របស់ម៉ាស៊ីនរណប បរាជ័យក្នុងការអនុលោមតាមនូវការធានាណាមួយដែលអាចអនុវត្តបាន អ្នកអាចប្រាប់ដំណឹងនេះឲ្យ Apple បានដឹង ហើយ Apple នឹងប្រគល់ប្រាក់ឲ្យអ្នកវិញនូវថ្លៃទិញគ្រឿងទន់ម៉ាស៊ីនរណបបែបនេះដែលអ្នកបានចំណាយ ហើយតាមកម្រិតអតិបរមាអនុញ្ញាតដោយច្បាប់ដែលអាចយកមកអនុវត្តបាន Apple នឹងមិនមានកាតព្វកិច្ចអ្វីឡើយលើការធានាផ្សេងណាមួយ ចំពោះគ្រឿងទន់របស់ម៉ាស៊ីនរណប ។ និង (ii) Apple និងសាខារបស់ខ្លួន គឺជាអត្ថាគាហកតតីយជននៃកិច្ចព្រមព្រៀង ហើយមានសិទ្ធិ (**ហើយនឹងចាត់ទុកថាបានទទួលយកសិទ្ធិ**) ដើម្បីពង្រឹងកិច្ចព្រមព្រៀងនេះ ក្នុងនាមជាហត្ថាគាហកតតីយជន ។

តាមរយៈការចុច "ខ្ញុំយល់ព្រម" ខាងក្រោម ឬដោយការតម្លើង ការធ្វើឲ្យដំណើរការ ឬការប្រើសូហ្វែរសម្រាប់ម៉ាស៊ីនរណបណាមួយ មានន័យថាអ្នក ទទួលស្គាល់ថា អ្នកបានអាន យល់ និងយល់ព្រមភ្ជាប់ខ្លួន និងអនុលោមតាមកិច្ចព្រមព្រៀងនេះ និងបង្ហាញប្រាប់ក្រុមហ៊ុន BLACKBERRY ថ អ្នកពេញចិត្តនឹងល័ក្ខខ័ណ្ឌ (ក) ឬ (ខ) ខាងលើ
**ប្រសិនបើអ្នកមិនយល់ព្រមនឹងល័ក្ខខ័ណ្ឌនេះ ឬអ្នកមិនបំពេញតាមល័ក្ខខ័ណ្ឌណាមួយខាងលើ អ្នកអាចតម្លើង ធ្វើឲ្យដំណើរការ ឬប្រើសូហ្វែរសម្រាប់ម៉ាស៊ីនរណបឡើយ ។**